**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

លេខ : ១៥៣ បទ.ប្រក

"...ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធភាព"

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងសេវាទូរស័ព្ទអចល័តឥតប្រើខ្សែ

( Fixed Wireless Local Loop « FWLL » )

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា,
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ខែសីហាឆ្នាំ២០០២ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ.បក ចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ ស្តីពីការដំឡើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញអនុក្រឹត្យលេខ ១៨១ អនក្រ.បក ចុះថ្ងៃទី០៣ខែវិច្ឆិកាឆ្នាំ២០០៨ ស្តីពីការដំឡើងអធិការដ្ឋានទៅជាអគ្គាធិការដ្ឋាននៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,

- បានឃើញសេចក្ដីសម្រេចលេខ ១៩៤ បទ.សសរ ចុះថ្ងៃទី០៩ខែកញ្ញាឆ្នាំ២០០៩ ស្ដីពីការបង្កើតក្រុមការងាររបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ដើម្បីរៀបចំគោលនយោបាយថ្មីនៃការតភ្ជាប់បណ្ដាញនិងអាជីវកម្មទូរគមនាគមន៍,
- បានឃើញសាពចរអន្តរក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍លេខ ១២៧៧ ស.ហ.វ.-ប.ទ. ចុះថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០០៩ ស្ដីពីវិធានការទប់ស្កាត់ភាពពុំស្មោះត្រង់ នៃការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍,
- បានឃើញប្រកាសលេខ ២០៦ បទ.ប្រក ចុះថ្ងៃទី០៥ខែតុលាឆ្នាំ២០០៩ ស្ដីពីការតភ្ជាប់បណ្ដាញទូរគមនាគមន៍របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៣២ ស.ហ.វ.-ប.ទ. ចុះថ្ងៃទី០៧ខែធ្នូឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្ដីពីការកំណត់ថ្លៃអប្បបរមានៃសេវាទូរស័ព្ទចល័ត អចល័ត និង ថ្លៃតភ្ជាប់បណ្ដាញ,
- បានឃើញសេចក្ដីជូនដំណឹងលេខ ៦៧៧ សជណ ចុះថ្ងៃទី១១ខែមិថុនាឆ្នាំ២០១០ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី ស្ដីអំពីករណីបញ្ហាវិវាទនៃការទូទាត់តម្លៃសន្ទនាឆ្លងកាត់បណ្ដាញរវាងបណ្ដាក្រុមហ៊ុនទូរស័ព្ទនានាជាមួយនិងក្រុមហ៊ុនវៀតថែលកម្ពុជា,
- បានឃើញលិខិតលេខ ៨៧៧ បទ ចុះថ្ងៃទី២៣ខែមិថុនាឆ្នាំ២០១០ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្ដីអំពីការប្រើប្រាស់បច្ចេកវិទ្យា Wireless Local Loop និង ការដោះស្រាយបញ្ហាវិវាទ,
- បានឃើញប្រកាសលេខ ១០៥ បទ.ប្រក ចុះថ្ងៃទី១០ខែឧសភាឆ្នាំ២០១០ របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ស្ដីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់របស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍,
- យោងសេចក្ដីត្រូវការចាំបាច់។

**សម្រេច**

**ប្រការ ១** : ប្រកាសនេះមានគោលបំណងកំណត់ល័ក្ខខ័ណ្ឌក្នុងការពង្រីងប្រតិបត្តិការ និង ការគ្រប់គ្រងសេវាទូរស័ព្ទអចល័តឥតប្រើខ្សែ ( Fixed Wireless Local Loop )។

**ប្រការ ២** : ពាក្យបច្ចេកទេសទាំងឡាយដែលប្រើក្នុងប្រកាសនេះមានន័យដូចតទៅ៖

១ ) **សេវាទូរសព្ទអចល័ត** ( Fixed Phone Service )

សំដៅលើសេវាទូរស័ព្ទដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍ជូនអតិថិជនដោយប្រើខ្សែ ឬ ឥតប្រើខ្សែដែលមានទីតាំងនៅទីងមួយកន្លែងតាមប្លង់លេខទូរស័ព្ទជាតិ និង ផុយពីសេវា ទូរសព្ទចល័ត។

២ ) **ប្លង់លេខទូរស័ព្ទជាតិ** ( National Telephone Numbering Plan )

សំដៅលើតារាងលេខទូរស័ព្ទថ្នាក់ជាតិកំណត់សម្រាប់ប្រទេសកម្ពុជាប្រើប្រាស់តាមនិយាមបច្ចេកទេសទូរគមនាគមន៍អន្តរជាតិ ដើម្បីសម្គាល់ប្រភេទសេវាភ្ជាប់សន្ទនាការក្នុង និង ក្រៅប្រទេស។

៣ ) **បណ្តាញបមាណីទូរស័ព្ទសាធារណៈ** ( Public Switched Telephone Network « PSTN » )

សំដៅលើបណ្តាញទូរស័ព្ទសម្រាប់បម្រើសេវាសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា។

៤ ) **ទូរស័ព្ទអចល័តឥតប្រើខ្សែ** ( Fixed Wireless Local Loop « FWLL ឬ WLL » )

សំដៅលើទូរស័ព្ទអចល័តដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនទូរគមនាគមន៍ ហើយប្រើប្រព័ន្ធវិទ្យុតភ្ជាប់ ( Radio Access ) ឬ បច្ចេកវិទ្យាទំនើបចម្រុះ ( ដូចជាប្រព័ន្ធ GSM, CDMA, 3G ជាដើម ) ជូនអតិថិជនតាមគេហដ្ឋាន ឬ តាមក្រុមហ៊ុនអាជីវកម្មដែលមានអាសយដ្ឋានច្បាស់លាស់ រួចត្រូវបានតភ្ជាប់ទៅនឹងបណ្តាញបមាណីទូរស័ព្ទសាធារណៈស្របតាមផែនការបច្ចេកទេសដោយមានការយល់ព្រមពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។

៥ ) **រង្វង់មួយស្ថានីយវិទ្យុ** ( Single Home Cell )

សំដៅលើដែនវិទ្យុសម្រាប់បម្រើសេវាទូរស័ព្ទអចល័តឥតប្រើខ្សែដែលអតិថិជនមានទីតាំងអាចហៅទូរស័ព្ទចេញ-ចូលបានក្នុងរង្វង់តែមួយស្ថានីយវិទ្យុនៃប្រព័ន្ធទូរស័ព្ទអចល័តឥតប្រើខ្សែនោះ។

៦ ) **វិញ្ញាបនប័ត្របញ្ជាក់អនុញ្ញាតលើប្រភេទ** ( Type Approval Certificate )

*សំដៅលើវិញ្ញាបនប័ត្រដែលបានផ្តល់ចំពោះឧបករណ៍បានចុះបញ្ជីដែលគោរពតាមលក្ខណៈសម្បត្តិសម្រាប់ប្រើនៅក្នុងប្រទេសកម្ពុជា។*

៧ ) **បរិធានទូរស័ព្ទអចល័តឥតប្រើខ្សែ** ( Fixed Wireless Terminal )

*សំដៅលើបរិធានទូរស័ព្ទអចល័តឥតប្រើខ្សែដាក់នៅទីងមួយកន្លែងតាមគេហដ្ឋាន ឬ តាមក្រុមហ៊ុនអាជីវកម្មដែលមានអាសយដ្ឋានច្បាស់លាស់។*

**ប្រការ ៣** : *ក្រុមហ៊ុនទូរស័ព្ទចល័តកំពុងបម្រើសេវាទូរស័ព្ទដែលពុំមានអាជ្ញាប័ណ្ណ* WLL *ហើយមានគម្រោងផ្លាស់ប្តូរ ឬ ធ្វើសមាហរណកម្មបច្ចេកវិទ្យាទំនើប ដើម្បីបម្រើសេវា* WLL *ចាំបាច់ត្រូវសុំអាជ្ញាប័ណ្ណជាមុនពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។*

**ប្រការ ៤** : *សេវាទូរស័ព្ទអចល័តឥតប្រើខ្សែ ត្រូវបានកំណត់ព្រំដែននៃការប្រើប្រាស់ក្នុងរង្វង់តែមួយស្ថានីយវិទ្យុ* ( Single Home Cell ) *នៃប្រព័ន្ធទូរស័ព្ទនេះតែប៉ុណ្ណោះ។*

**ប្រការ ៥** : *បរិធានទូរស័ព្ទអចល័តឥតប្រើខ្សែ ចាំបាច់ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់អនុញ្ញាតលើប្រភេទពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។*

**ប្រការ ៦** : *ថ្លៃតភ្ជាប់បណ្តាញចេញនិងចូលនៃទូរស័ព្ទអចល័តឥតប្រើខ្សែ ត្រូវអនុវត្តតាមស្មារតីនៃប្រកាសអន្តរក្រសួងលេខ ២៣២ ស.ហ.វ.-ប.ទ. ចុះថ្ងៃទី០៧ខែធ្នូឆ្នាំ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ស្តីពីការកំណត់ថ្លៃអប្បរមានៃសេវាទូរស័ព្ទចល័ត អចល័ត និង ថ្លៃតភ្ជាប់បណ្តាញ។*

**ប្រការ ៧** : *រូបវន្តបុគ្គល ឬ នីតិបុគ្គលណាដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ រកឃើញថាប្រព្រឹត្តល្មើស ឬ ក្លែងបន្លំដោយផ្តល់សេវាផ្ទុយពីខ្លឹមសារនៃប្រកាសនេះ នឹងត្រូវផ្អាកអាជ្ញាប័ណ្ណមិនឱ្យដំណើរការជាបន្ទាន់។*

**ប្រការ ៨** : *រាល់ប្រកាស និង លិខិតបទដ្ឋានទាំងឡាយណា ដែលផ្ទុយពីខ្លឹមសារនៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។* ៚

---

**ប្រការ ៩** : ខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល អគ្គនាយកដ្ឋានប.ទ. អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន គ្រប់មន្ទីរប.ទ.ខេត្តក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ព្រមទាំងក្រុមហ៊ុនទូរគមនាគមន៍ទាំងអស់ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ ១០** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែសីហា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

ស៊ូ ខុន

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

  « ដើម្បីជូនជ្រាប »
- ដូចប្រការ ៩ « ដើម្បីអនុវត្ត »
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ